

តាម៉ុក ត្រូវបានចាប់ខ្លួននិងដាក់ក្នុងពន្ធនាគារយោធានៅក្នុងរាជធានីភ្នំពេញ រហូតដល់គាត់ទទួលមរណភាពនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦។ នៅថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ តុលាការខ្មែរក្រហម បានសម្រេចផ្តន្ទាទោស អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលកំពុងរស់រានមានជីវិត រួមមាន៖ នួន ជា និងខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តនៅតាមទីកន្លែងនានានៅទូទាំងប្រទេសកម្ពុជា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ អង្គជំនុំជម្រះបានសម្រេចផ្តន្ទាទោស នួន ជា និងខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត។

Ta Mok had been placed in military detention center in Phnom Penh until he passed away on 21 July 2006. On Friday 16 November, 2018, the Khmer Rouge Tribunal convicted former senior Khmer Rouge leaders Nuon Chea and Khieu Samphan of genocide, crimes against humanity and grave breaches of the Geneva Conventions of 1949. The crimes were committed at various locations throughout Cambodia during the Democratic Kampuchea period from 17 April 1975 to 6 January 1979. The Trial Chamber sentencing both Nuon Chea and and Khieu Samphan to life imprisonment.




ខៀវ សំផន ប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ
Khieu Samphan
Head of State of Democratic Kampuchea of Pol Pot

នួន ជា អនុលេខាបក្សកុម្មុយនីស្តកម្ពុជា
Nuon Chea
Deputy Secretary of the Communist Party of Kampuchea

Copyright and photo credit: James Gerrand/DC-Cam Archives



# តាម៉ុក

ឈ្មោះដើម
ឈិត ជឿន ឬ
អ៊ុង ជឿន

# TA MOK

Original Name:
Chhit Choeun or Ung Choeun

## TA MOK & His Comrades, Nuon Chea and Khieu Samphan

តាម៉ុក ហៅ តា១៥ ឬ ងួន កង មានឈ្មោះដើម ឈិត ជឿន ឬ អ៊ុង ជឿន កើតឆ្នាំ១៩២៦ នៅភូមិប្រគាប ឃុំត្រពាំងធំត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ជាកូនច្បងក្នុងចំណោមបងប្អូន៧នាក់ មានឪពុកឈ្មោះ អ៊ុង ប្រាក់ នឹងម្តាយឈ្មោះ អ៊ុក សុច។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៤០ តាម៉ុក បានចូលបម្រើក្នុងចលនាតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំងនិងជប៉ុននិងត្រូវបានចាត់តាំងជាប្រធានចលនាខ្មែរឥស្សរៈស្រុកត្រាំកក់នៅឆ្នាំ១៩៤៩។ នៅឆ្នាំ១៩៥៤ ពេលដែលប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំង តាម៉ុក បានបួសជាសង្ឃនៅក្នុងខេត្តកំពង់ស្ពឺ និងបានបន្តសកម្មភាពនយោបាយដោយសម្ងាត់។ ក្នុងឆ្នាំ១៩៦៦ តាម៉ុក មានតួនាទីជាលេខាបក្សកុម្មុយនីស្តកម្ពុជា ប្រចាំភូមិភាគនិរតី។ ក្នុងឆ្នាំ១៩៧២ តាម៉ុក មានជាប់ទាក់ទងនឹងការបញ្ជាឱ្យវាយប្រហារជាលើកដំបូងទៅលើវប្បធម៌ និងទំនៀមទម្លាប់របស់ជនជាតិចាមនៅក្នុងប្រទេសកម្ពុជា។ នៅខែមីនា ឆ្នាំ១៩៧៤ តាម៉ុក សហការជាមួយ កែ ពក បានដឹកនាំកម្លាំងចូលកាន់កាប់ឧត្តុង្គ និងបានបង្ខំឲ្យប្រជាជនប្រមាណ២ម៉ឺននាក់ជម្លៀសចេញទៅកាន់ទីជនបទ ជាកន្លែងដែលអ្នកជម្លៀសទាំងនោះត្រូវបានសម្លាប់និងបង្អត់អាហារ។ ពីឆ្នាំ១៩៧៥ដល់១៩៧៧ ក្នុងនាមជាលេខាភូមិភាគនិរតី តាម៉ុក ជាប់ទាក់ទងនឹងការសម្លាប់រង្គាលប្រជាជនកម្ពុជា រួមទាំងការសម្លាប់មនុស្សប្រមាណ៣ម៉ឺននាក់នៅក្នុងស្រុកអង្គរជ័យ។ នៅចុងឆ្នាំ១៩៧៨ តាម៉ុក បានទទួលបញ្ជាឲ្យកាន់កាប់ភូមិភាគពាយ័ព្យ ដើម្បីបោសសម្អាតខ្មាំងក្បត់អង្គការ។ ក្នុងឆ្នាំដដែល តាម៉ុក ត្រូវបានតែងតាំងជាអនុលេខាទីពីរនៃបក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩ តាម៉ុក បានភៀសខ្លួនទៅកាន់ភាគខាងលិចប្រទេស ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ហើយបានគ្រប់គ្រងកម្លាំងយោធានៅទីនោះរហូតដល់ពេលចាប់ខ្លួនដោយកងកម្លាំងរាជរដ្ឋាភិបាល នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩។ តាម៉ុក ត្រូវបញ្ជូនមកដាក់ក្នុងមន្ទីរឃុំឃាំងនៅភ្នំពេញ រហូតដល់ស្លាប់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦។

The original name of Ta Mok, alias Ta 15 or Nguon Kang, was Chhit Choeun or Ung Choeun. He was born in 1926 in Prakeap village, Trapeang Thom Tbaung commune, Tram Kak district, Takeo Province. He was the eldest son among 7 siblings whose father and mother were Ung Prak and Uch Soch, respectively. In around 1940s, Ta Mok started serving in the movement against French and Japanese Colonization; he, then, became the chief of Khmer Issarak Movement in Tram Kak district in 1949. In 1954, when Cambodia obtained the independence from France, Ta Mok ordained as a monk in Kampong Speu province and continued his political activities secretly. In 1966, Ta Mok held the position of secretary to the Communist Party of Kampuchea (CPK) based in Southwest Zone. In 1972, Ta Mok involved in issuing an order of the very first invasion on culture and tradition of Cham ethnicity in Cambodia. In March 1974, Ta Mok collaborated with Ke Pauk to lead the forces to take over Oudong and forced approximately 20,000 people to evacuate to rural areas where those evited people were killed or starved to death. From 1975 to 1977, in the name of secretary to Southwest Zone, Ta Mok engaged in the mass killing of Cambodians, consisted of the killing of around 30,000 people in Angkor Chey district. At the end of 1978, Ta Mok received the order to control over Northwest Zone to sweep up all Angkar's traitors. In the same year, Ta Mok was appointed to be the Second Secretary to CPK. After Khmer Rouge regime failed in January 1979, Ta Mok fled to western part of the country, i.e. in Anlong Veng district, Oddar Meanchey province, and he controlled over military forces at the stated location until he was arrested by the royal government forces on 6 March 1999. Ta Mok had been placed in detention center in Phnom Penh until he passed away on 21 July 2006.


ទីស្តីការគណៈរដ្ឋមន្ត្រី

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

Office of the Council of Ministers

TO
SAMDECH AKKA MOHA SENA PADEI TECHO HUN SEN
PRIME MINISTER OF THE KINGDOM OF CAMBODIA

Objective : Report about the meeting of Inter-Ministry Committee on the Management and Development of Anlong Veng Historical Sites in Anlong Veng district, Oddar Meanchey province.
Reference : Letter no. 050. របក dated 24 July 2015 of the Ministry of Tourism

As stated in the above-mentioned objective and reference, I would like to inform Samdech Techo Prime Minister that on 8 July 2015 in Anlong Vengdistrict, Oddar Meanchey province, Inter-Ministry Committee on the Management and Development of Anlong Veng Historical Sites held a meeting on the preservation, management and development of the Anlong Veng historical sites in a more effective and sustainable manner. Present at the meeting were 41 members and representatives of the Committee.

The discussion and result of the meeting are as follows:
- Approval of the request of His Excellency Sar Thavy, Oddar Meanchey Provincial Governor, on the setting up of a provincial working group to oversee the delimitation of Anlong Veng historical sites.
- Approval of a feasible study for development by Mr. Youk Chhang, director of Documentation Center of Cambodia (DC-Cam) on Site«ក១» (Pol Pot's Cremation Site), Site«ក៣» (Ta Mok's House on Dang-rek mountain), Site«ខ១»(Son Sen's Cremation Site), and Site«ខ៥»(Ta Mok's House, Ta Mok's Museum). This should adhere to the original style with a clear plan being submitted to the Royal Government of Cambodia (RGC) for approval.
- Approval of road construction bound for all of the 14 historical sites, as stated in the RGC's sub-degree on the Anlong Veng Historical Sites.
- There need to be an approval from the Ministry of Water Resources and Meteorology in regard to the earth digging to build a road on the Anlong Veng lake's bank.
- Installation of markers at all 14 historical sites with signposts.
- Ministry of Tourism, Documentation Center of Cambodia, and Oddar Meanchey Provincial Hall to work collaboratively to organize a community tour guide training, using the community tour guide uniform.

As mentioned above, I would like Samdech Techo Prime Minister to be kindly informed and to seek your highly valuable advice.

Seen
5.8.15

(signed)

With Highest Regards,
Phnom Penh, 4 August 2015
Acting Minister

(signed)

Bun Uy



Photo: Ta Mok's House
Ouch Makara

**ANLONG VENG PEACE CENTER**
**EXHIBITION 2019:** Youk Chhang
**RESEARCH:** Long Dany, Pheng Pong-Rasy, Som Bunthorn
with Comrade Kong (DK Foreign Affairs: 1975-6 January 1979)
**FOR MORE INFORMATION:** Dr. Ly Sok-Kheang, Director
t: +855 12 570 465 - truthlysokkheang@dccam.org